**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ខែកក្កដា ឆ្នាំ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jul-2015, 14:26
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបង្ហាញផ្នែកខ្លះៗ នៃឯកសារលេខ E307/5.2.8 ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Henri DECOEUR

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គុត

Marie GUIRAUD

អនុលោមតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[1] សហមេធាវីការពារក្ដីលោក នួន ជា ("មេធាវីការពារក្ដី") សូមដាក់ការបង្ហាញនូវផ្នែកខ្លះៗនៃឯកសារ E307/5.2.8 ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីសុំឲ្យទទួលយកនៅក្នុងសំណុំរឿង ០០២/០២៖

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានណែនាំភាគីទាំងអស់ឲ្យផ្ដល់នូវបញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាព ដែលបានដាក់ពីមុន និង បញ្ជីវត្ថុតាងដែលភាគីមានបំណងដាក់បង្ហាញដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់សំណុំរឿង ០០២/០២។ មេធាវីការពារក្ដីបានដាក់បញ្ជីឯកសាររបស់ខ្លួនដែលបានធ្វើបច្ចុប្បន្នភាព នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤[2]។ បញ្ជីនេះរួមមានឯកសារ E307/5.2.8 ជាកម្រងជីវប្រវត្តិចំនួន ២១ ("Kurzbiographies") ដែលបានផលិតឡើងដោយក្រសួងសន្តិសុខរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់[3]។

2. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យភាគីទាំងអស់មានឱកាសដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរចំពោះឯកសារនានា ដែលមានក្នុងបញ្ជីឯកសាររបស់ភាគីផ្សេងទៀតដែលបានធ្វើបច្ចុប្បន្នភាព[4]។ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចរបស់ខ្លួនទៅលើភាពអាចទទួលយកបាននៃឯកសារនានាដែលមានក្នុងបញ្ជីឯកសាររបស់ភាគីដែលបានធ្វើបច្ចុប្បន្នភាព ការជំទាស់របស់ភាគីទៅនឹងបញ្ជីទាំងនោះ និងទៅលើសេចក្ដីសន្និដ្ឋានផ្សេងៗទៀតរបស់ភាគី[5]។

3. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំថា មេធាវីការពារក្ដីគួរដាក់ការបង្ហាញនូវផ្នែកខ្លះៗនៃឯកសារ E307/5.2.8 ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំ

---

[1] ឯកសារ **E305/17** "សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ("សេចក្ដីសម្រេច") កថាខណ្ឌ ២៨ ដល់ ៣០។

[2] ឯកសារ **E307/5** "បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ("បញ្ជីឯកសាររបស់ នួន ជា")។

[3] ឯកសារ **E307/5.2** "ឧបសម្ព័ន្ធ ក៖ បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ លេខ ERN 01000972 (ភាសាអង់គ្លេស)។

[4] ឯកសារ **E327** "ការកំណត់កាលបរិច្ឆេទសម្រាប់ដាក់ការជំទាស់ទៅនឹងឯកសារនានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៤ ដល់ ៦។

[5] ឯកសារ **E305/17** សេចក្ដីសម្រេច កថាខណ្ឌ ៦។

ជម្រះសាលាដំបូង ក្នុងរយៈពេល ១៤ ថ្ងៃ[6]។

## II. ការបង្ហាញផ្នែកខ្លះៗនៃឯកសារ E307/5.2.8 ដែលមេធាវីការពារក្តី នួន ជា មានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ

4. នាពេលបច្ចុប្បន្ន ឯកសារ E307/5.2.8 ជាឯកសារតែមួយគត់ដែលមានជាភាសាអាល្លឺម៉ង់។ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃថាតើឯកសារនេះជាប់ពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ នោះ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំថា មេធាវីការពារក្តីគួរដាក់ការបង្ហាញផ្នែកខ្លះៗនៃឯកសារនេះ ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[7]។

5. នាពេលនេះ មេធាវីការពារក្តីសូមដាក់ការបង្ហាញនូវផ្នែកខ្លះៗនៃឯកសារនេះ។ ផ្នែកទាំងនេះមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ក នៃសារណានេះ (“ការបង្ហាញ”)។ អនុលោមទៅតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ការបង្ហាញរួមមាន ការអធិប្បាយពិស្តារពីលក្ខណៈ និងខ្លឹមសារនៃផ្នែកនីមួយៗ រួមទាំងសម្រង់ចំណុចនានាដែលពាក់ព័ន្ធពីក្នុងដីកាដំណោះស្រាយ តាមតែអាចធ្វើទៅបាន[8]។ ជាងនេះទៀត ផ្នែកនីមួយៗត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមរម្យដោយមានលេខយោងឯកសារចំណងជើង ភាសានៃឯកសារ កថាខណ្ឌជាក់លាក់ពីក្នុងដីកាដំណោះស្រាយ និងបទចោទជាក់លាក់ តាមតែអាចធ្វើទៅបាន[9]។

សហមេធាវីការពារក្តីលោក នួន ជា

សុន អរុណ

Victor KOPPE

[6] ឯកសារ **E305/17** សេចក្តីសម្រេច កថាខណ្ឌ ២៩ ដល់ ៣០។

[7] ឯកសារ **E305/17** សេចក្តីសម្រេច កថាខណ្ឌ ២៩ ដល់ ៣០។

[8] ឯកសារ **E305/17** សេចក្តីសម្រេច កថាខណ្ឌ ២៩។

[9] ឯកសារ **E305/17** សេចក្តីសម្រេច កថាខណ្ឌ ២៩ ជើងទំព័រ ៦០។ ឯកសារ E305 “ដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២” ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១១។